**Please print the letter below and photocopy onto school letterhead before distribution**

លិខិតជម្រាបមាតាបិតាអំពីព្រឹត្តិការណ៍សហគមន៍នៅពេលថ្មីៗ
Letter to parents regarding recent community events

ជម្រាបមកដល់មាតាឬបិតា/អ្នកថែទាំ

ជាការឆ្លើយតបនឹងព្រឹត្តិការណ៍សហគមន៍នៅពេលថ្មីៗនេះ នៅថ្ងៃនេះសាលារៀនរបស់លោកអ្នកបានចាត់ឲ្យមានវិធានការដូចតទៅ។

សិស្សបានទទួលការធានាថា សាលារៀននឹងជាមជ្ឈដ្ឋានមានសុវត្ថិភាពតទៅទៀតសម្រាប់ជនរាល់រូប។ សិស្សបានទទួលការរំលឹកអំពីមាត្រាទាំងពួងនៃគោលការណ៍ប្រឆាំងនឹងការប្រកាន់ជាតិសាសន៍និងសុខុមាលភាពដែលធានាថា សិស្សនឹងទទួលជំនួយបើសិស្សជួបប្រទះនឹងការយាយីរំខានផ្ទាល់ខ្លួនណាមួយ។

សិស្សបានទទួលឱកាសដើម្បីនិយាយអំពីអារម្មណ៍របស់ខ្លួន ហើយបានទទួលការរំលឹកថា គេអាចទាក់ទងអ្នកពិគ្រោះយោបល់ឬបុគ្គលិកឯទៀតរបស់សាលារៀន បើសិនជាគេមានការបារម្ភឬអាក់អន់ចិត្ត។ សាលារៀននឹងផ្តល់ជំនួយតទៅទៀតទៅឲ្យសិស្សណាមួយដែលត្រូវការជំនួយ។

ជាការមានប្រយោជន៍បើសិនជាលោកអ្នកអាចពិភាក្សាជាមួយកូនលោកអ្នកអំពីព្រឹត្តិការណ៍ទាំងនេះ ព្រមទាំងលើកទឹកចិត្តកូនឲ្យអនុវត្តតទៅទៀតនូវការអនុគ្រោះយោគយល់និងការយកចិត្តទុកដាក់ចំពោះជនគ្រប់រូបទាំងនៅសាលារៀន និងទាំងនៅក្នុងសហគមន៍ធំទូលាយ។

ការរក្សាសកម្មភាពនិងចំណាប់អារម្មណ៍ជាធម្មតាទាំងឡាយនៅឯផ្ទះ ផ្តល់ប្រយោជន៍ដល់កុមារដែលកំពុងដោះស្រាយស្ថានការណ៍លំបាកទាំងឡាយ។

សូមទាក់ទងសាលារៀន បើសិនជាលោកអ្នកមានសេចក្តីបារម្ភជាក់លាក់ណាមួយអំពីកូនលោកអ្នក ហើយសាលារៀននឹងផ្តល់ជំនួយឲ្យបានរហ័សតាមលទ្ធភាព។

បើលោកអ្នកត្រូវការអ្នកបកប្រែភាសាដើម្បីជួយលោកអ្នកក្នុងការទាក់ទងសាលាលរៀន សូមទូរសព្ទទៅសេវាបកប្រែភាសាតាមទូរសព្ទដែលមានលេខ 131 450 ហើយសុំអ្នកបកប្រែភាសាលោកអ្នក។ ការិទូរសព្ទនឹងរៀបចំឲ្យមានអ្នកបកប្រែភាសានៅចាំតាមទូរសព្ទ ដើម្បីជួយដល់ការសន្ទនារបស់លោកអ្នក។ លោកអ្នកនឹងមិនបង់ថ្លៃសេវានេះទេ។

ដោយសេចក្តីគោរពស្មោះស្ម័គ្រ

នាយកសាលា (Principal)